ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


បេឡាជាតិរបបសន្តិសុខសង្គម

លេខ :១៤/......ប.ស.ស
/១០


# សេចក្តីជូនដំណឹង

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) មានកិត្តិយសសូមជម្រាបជូនដល់លោក លោកស្រី នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ជ្រាបថាៈ កន្លងមកការចម្លងទិន្នន័យ(E-Form)មកកាន់ប.ស.ស របស់សហគ្រាស គ្រឹះស្ថានមួយចំនួនបានដាក់ចូលទៅ Flash ឬ External Hard Disk ដែលមានទិន្នន័យច្រើននៅក្នុងនោះ ដែលជាហេតុត្រូវការចំណាយពេលវេលាច្រើនក្នុងការScan virus និងអាចធ្វើឱ្យបាត់បង់ទិន្នន័យដែលមាននៅក្នុងនោះ។ អាស្រ័យហេតុនេះ ដើម្បីឱ្យដំណើរការនៃការពិនិត្យទិន្នន័យមានភាពរលូន឵ឆាប់រហ័ស និងមិនចំណាយពេលវេលារង់ចាំយូរ ប.ស.ស សូមស្នើសុំ លោក/លោកស្រី នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់មេត្តាអនុវត្តន៍តាមការណែនាំដូចខាងក្រោមៈ

១- ត្រូវមាន Flash មួយដោយឡែកសម្រាប់ប្រើប្រាស់ក្នុងទំនាក់ទំនងការងារជាមួយប.ស.ស

២- Flash នោះមិនត្រូវផ្ទុកទិន្នន័យផ្សេងក្រៅពី E-Form ឬទិន្នន័យសម្រាប់ខែដែលត្រូវបង់ភាគទាននោះឡើយ

៣- សូមប្រើប្រាស់ E-Form ថ្មី ដោយសារE-Formថ្មីមានទំហំតូចសមល្មម (268KB)

ក្នុងករណីដែលលោក/លោកស្រីនៅតែប្រើប្រាស់ Flash ដែលមានផ្ទុកទិន្នន័យផ្សេងៗក្រៅពីទិន្នន័យដូចបានណែនាំខាងលើ នោះប.ស.សពុំទទួលខុសត្រូវរាល់ការបាត់បង់ទិន្នន័យទាំងនោះឡើយ។

ទទួលបានសេចក្តីជូនដំណឹងនេះ ប.ស.សមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ នឹងចូលរួមសហការអនុវត្តន៍ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់និងដោយការយោគយល់។

សូមលោក/លោកស្រី នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០

នាយក

អ៊ុក សមវិជ្ជា